01653095

លេខ / N°: D363/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 08 / 2020
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស

| | |
|---|---|
| នៅចំពោះមុខ ៖ | សហចៅក្រមស៊ើបអង្កេត |
| កាលបរិច្ឆេទឯកសារ ៖ | ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ |
| ភាសា៖ | ខ្មែរ និង អង់គ្លេស |
| ចំណាត់ថ្នាក់ប្រភេទឯកសារ៖ | សាធារណៈ |

# ដីកាបង្គាប់ឲ្យដោះលែង និងដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ

<u>ផ្ញើជូន៖</u>

សហព្រះរាជអាជ្ញា
ជា លាង
Brenda HOLLIS

**មេធាវីការពារក្តី អោ អាន**
**មុំ លុជ្ស**
Richard ROGERS
Göran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីន៉ែន
ទី ស្រ៊ីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARTI

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ ("អ.ប.ជ") បានចេញសេចក្ដីពិចារណារបស់ខ្លួន ("សេចក្ដីពិចារណា") លើបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី អោ អាន ("មេធាវីការពារក្ដី") និង របស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះអាជ្ញាអន្តរជាតិ ("ស.ព.ជ" និង "ស.ព.អ") ដែលចៅក្រមនៃអង្គជំនុំជម្រះនេះ យល់ស្របរួមគ្នាថា ដីកាដំណោះស្រាយ ("ដីកាដំណោះស្រាយ") ដាច់ដោយឡែកពីគ្នា ជារឿងខុសច្បាប់ តែមិនទទួលបានសំឡេងគាំទ្រភាគច្រើន ដែលចាំបាច់ដើម្បីសម្រេចលើអង្គសេចក្ដីទេ ផ្ទុយទៅវិញ បានតម្កល់ដីកាដំណោះស្រាយនីមួយៗ ទៅតាមការយល់ឃើញរបស់ចៅក្រមរៀងៗខ្លួន[1]។

២. ស.ព.អ បានស្នើសុំឲ្យ អ.ប.ជ បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទៅអង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ជ") ចំណែកមេធាវីការពារក្ដី បានស្នើសុំឲ្យ អ.ប.ជ ដាក់បញ្ចូលសំណុំរឿងទៅក្នុងបណ្ណសារ។ មានការបញ្ជូនឯកសារនានាទៅ អ.ជ.ស.ជ ផងដែរ ដើម្បីទទួលបានការប្រកាសពី អ.ជ.ស.ជ ថាតើអង្គជំនុំជម្រះយល់ថាខ្លួន បានទទួលដីកាបញ្ជូនរឿងទៅជំនុំជម្រះឬយ៉ាងណា។

៣. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០ អ.ជ.ស.ជ បានចេញសេចក្ដីថ្លែងការណ៍មួយ ដែលមានខ្លឹមសារថា ទោះបីចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះ មានបំណងរៀបចំឲ្យមានការពិភាក្សាបឋមទៅលើបញ្ហានានា ដែលភាគី បានលើកឡើងក្ដី តែចៅក្រមជាតិនៃអង្គជំនុំជម្រះ បានបដិសេធយ៉ាងដាច់អហង្ការ មិនប្រើប្រាស់វិធីសាស្ត្រនេះទេ ហើយប្រកាសថា នឹងពុំមានការជំនុំជម្រះក្ដី អោ អាន "នៅពេលនេះ ឬនៅពេលអនាគតឡើយ"[2]។

៤. នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ ចៅក្រម Michael Bohlander បានទទួលការតែងតាំងឲ្យកាន់តំណែងឡើងវិញ ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ("ស.ច.ស.អ")ពីអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៥. នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ មេធាវីការពារក្ដី បានដាក់ជាសម្ងាត់នូវសំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ នៅចំពោះមុខយើង ("សំណើ")[3]។ ពីដំបូង ឯកសារ

---

[1] ឯកសារ **D359/24 & D360/33** *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១២៣។

[2] ឯកសារ **D363/1.2.4** *ឯកសារយោង៤៖ សេចក្ដីថ្លែងការណ៍របស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ស្ដីពីសំណុំរឿង ០០៤/២ ពាក់ព័ន្ធនឹង អោ អាន ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០*។

[3] ឯកសារ **D363** *សំណើសុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

នេះបានដាក់ជាសម្ងាត់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ហើយបន្ទាប់មក ត្រូវបានធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ និងបានជូនដំណឹង នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០២០ ក្រោយពេលមានការតែងតាំង ស.ច.ស.អ ឲ្យចូលកាន់តំណែងឡើងវិញ។ ស.ព.អ[4] បានឆ្លើយតបទៅនឹងសំណើ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។ ស.ព.ជ មិនបានដាក់ចម្លើយតបទេ។ មេធាវីការពារក្តី បានធ្វើការឆ្លើយតបនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០[5]។

៦. នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ស.ព.អ បានដាក់បណ្តឹងសាទុក្ខជាបន្ទាន់ប្រឆាំងនឹងការរំលត់ជាស្ថាពរនៃសំណុំរឿង ០០៤/២ របស់ អ.ជ.ស.ដ[6]។ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០២០ យើងបានជូនដំណឹងដល់ភាគីថា យើងនឹងផ្អាកការចេញសេចក្តីសម្រេចរបស់យើងទៅលើសំណើនេះ ដោយរង់ចាំសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល("អ.ជ.ត.ក")[7]។

៧. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អ.ជ.ត.ក បានសម្រេចថា បណ្តឹងសាទុក្ខជាបន្ទាន់ អាចទទួលយកបាន និងបានបញ្ចប់សំណុំរឿងប្រឆាំង អោ អាន ដោយសារ ពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាព ដោយលើកឡើងថា អ.ប.ជ គួរចាត់ទុកដីកាដំណោះស្រាយទាំងពីរជាអាសារបង់ ហើយមិនគួរយកទៅពិភាក្សា លើអង្គសេចក្តីនៃដីកាទាំងនេះឡើយ[8]។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះ មិនបានបង្គាប់ជាផ្លូវការឲ្យដាក់បញ្ចូលសំណុំរឿងនេះទៅក្នុងបណ្ណសារទេ។

៨. សម្រាប់ព័ត៌មានលម្អិតស្តីពីប្រវត្តិនីតិវិធី យើងសូមយោងទៅកថាខណ្ឌ ២-៣៣ នៃសេចក្តីសម្រេចរបស់ អ.ជ.ត.ក។

---

[4] ឯកសារ **D363/1** *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ (ជាមួយឧបសម្ព័ន្ធសម្ងាត់ A1-K2)* ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០។

[5] ឯកសារ **D363/2** *ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន សុំដាក់បញ្ចូលសំណុំរឿង ០០៤/២ ទៅក្នុងបណ្ណសារ* ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២០។

[6] ឯកសារ **D363/1.1.11** *ឧបសម្ព័ន្ធ K1៖ បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០ ("បណ្តឹងសាទុក្ខជាបន្ទាន់របស់ ស.ព.អ ទៅ អ.ជ.ត.ក") កថាខណ្ឌ ១-៣, ៥០-៧៦* ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២០។

[7] ឯកសារ **D364** *អនុស្សរណៈពីសហចៅក្រមស៊ើបអង្កេតផ្ញើជូនភាគីទាំងអស់នៅក្នុងសំណុំរឿង ០០៤/២ និង អ.ជ.ត.ក* ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០។

[8] ឯកសារ **E004/2/1/1/2** *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពនៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ កថាខណ្ឌ ៥៣, ៧០, ៧១(vi)។

## II. ការពិភាក្សា

៩. ដោយផ្អែកលើសេចក្តីសម្រេចបញ្ចប់របស់ អ.ជ.ត.ក កិច្ចការដែលនៅសេសសល់របស់យើង គឺការបោះត្រា និងដាក់បញ្ចូលឯកសារសំណុំរឿងទៅក្នុងបណ្ណសារជាផ្លូវការ អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង ដែលអនុវត្តផងដែរក្នុងករណីនេះ ដោយសារ សេចក្តីសម្រេចបញ្ចប់សំណុំរឿង របស់ អ.ជ.ត.ក មិនស្ថិតក្នុងខ្លឹមសារនៃវិធាន ៦៧(៣) ឡើយ។

១០. អនុលោមតាមសំអាងហេតុទាំងនេះ យើង[9] ទទួលយកសំណើ និង បង្គាប់ឲ្យ បោះត្រា និងដាក់បញ្ចូលទៅក្នុងបណ្ណសារនូវសំណុំរឿង ០០៤/២។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

**សហចៅក្រមស៊ើបអង្កេត**
Co-Investigating Judges

**យូ ប៊ុនឡេង** Michael Bohlander

[9] ទោះបី ស.ច.ស ចេញសេចក្តីសម្រេចនេះរួមគ្នាក្តី តែ ស.ច.ស.ជ កត់សម្គាល់សម្រាប់ជាកំណត់ហេតុថា ឯកសារនានាដែលបានដាក់បញ្ចូលក្នុងសំណុំរឿង គួរត្រូវបានចុះលេខទៅតាមលំដាប់លំដោយពីឯកសារចុងក្រោយ ដែលបានដាក់មុនពេលចៅក្រម Siegfried Blunk លាឈប់ពីមុខតំណែង ដោយមិនរាប់បញ្ចូលនូវដីកា និងសេចក្តីសម្រេចនានា ដែលចេញដោយ ស.ច.ស បម្រុង Laurent Kasper-Ansermet ទេ។